ភ្នំពេញ ថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០១៦

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

# ពិធីប្រគល់វិញ្ញាបនបត្រភ្នាក់ងារសេវាកម្មពន្ធដារ ជំនាន់ទី៤ និងទី៥ របស់អគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

នាវេលាម៉ោង៨:៣០នាទីព្រឹក ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៦ នៅសាលាជាតិពន្ធដារ នៃអគ្គនាយកដ្ឋានពន្ធដារ មានរៀបចំពិធីប្រគល់វិញ្ញាបនបត្រ ជូនបេក្ខជន-បេក្ខនារីជ័យលាភី ដែលបានប្រឡងជាប់ស្ពាព ភ្នាក់ងារសេវាកម្មពន្ធដារជំនាន់ទី៤ និងទី៥ ក្រោមអធិបតីភាពរបស់ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ ព្រមទាំងមានការចូលរួមរបស់ថ្នាក់ដឹកនាំ នៃអគ្គនាយកដ្ឋានពន្ធដារ គ្រូឧទ្ទេសនាម សាលាជាតិពន្ធដារ និងមានការចូលរួមពីសំណាក់បេក្ខជន-បេក្ខនារីជ័យលាភី ដែលបានប្រឡងជាប់ស្ពាព ភ្នាក់ងារសេវាកម្ម ពន្ធដារជំនាន់ទី៤ និង ជំនាន់ទី៥ ចំនួន២១០នាក់ ផងដែរ។

ជាកិច្ចចាប់ផ្តើមឯកឧត្តម គង់ វិបុល បានសម្តែងកិច្ចស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមាន ថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន ដែលបានចូលរួមក្នុងពិធីនេះ និងសម្តែងការកោតសរសើរ ចំពោះលោកគ្រូឧទ្ទេសនាម សាលាជាតិពន្ធដារដែលបានខិតខំ យកអស់កម្លាំងកាយចិត្តក្នុងការបង្រៀន ផ្ទេរចំណេះដឹង និងបទពិសោធន៍ដល់សិក្ខាកាម និងកោតសរសើរ ចំពោះបេក្ខជន-បេក្ខនារីជ័យលាភី ដែលបានឆ្លៀតពេលពីកិច្ចការងារខិតខំប្រឹងប្រែងសិក្សារៀនសូត្រ រហូតបានទទួល លទ្ធផលប្រឡងជាប់ស្ពាពភ្នាក់ងារសេវាកម្មពន្ធដារ ដែលមានវត្តមានក្នុងពិធីប្រគល់ វិញ្ញាបនបត្រថ្ងៃនេះ។

ការប្រឡងភ្នាក់ងារសេវាកម្មពន្ធដារ តែងតែរៀបចំឡើង

ចំនួនពីរដងក្នុងមួយឆ្នាំ សម្រាប់សិក្ខាកាមដែលទទួលការបណ្តុះបណ្តាលនៅសាលាជាតិពន្ធដារ និងសាធារណជនទាំងអស់ ដែលមានបំណងចង់ក្លាយជាភ្នាក់ងារសេវាកម្មពន្ធដារ។ កន្លងមក សាលាជាតិពន្ធដារបានរៀបចំ ការប្រឡងភ្នាក់ងារសេវាកម្មពន្ធដារ បានចំនួន៥លើករួចមកហើយ ដែលមានបេក្ខជន-បេក្ខនារីប្រឡងជាប់សរុបចំនួន ៥១៦នាក់ ហើយក្នុងនោះបេក្ខជន-បេក្ខនារី ជ័យលាភីជំនាន់ទី៤ និងទី៥ ដែលមានចំនួនសរុប ២១០នាក់ ដែលត្រូវមកទទួលវិញ្ញាបត្រថ្ងៃនេះ សម្រាប់យកទៅប្រើប្រាស់ ស្នើសុំយកអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ នៅអគ្គនាយកដ្ឋានពន្ធដារ។ បេក្ខជន-បេក្ខនារីប្រឡងជាប់ ដែលនឹងក្លាយជាភ្នាក់ងារសេវាកម្មពន្ធដារ នឹងដើរតួនាទី យ៉ាងសំខាន់ក្នុងការជួយអ្នកជាប់ពន្ធ ឲ្យគោរពប្រតិបត្តិច្បាប់បានត្រឹមត្រូវ និងជួយលើកកម្ពស់វប្បធម៌នៃការបង់ពន្ធ ឲ្យកាន់តែល្អប្រសើរ។ ជាងនេះទៅទៀត ភ្នាក់ងារសេវាកម្មពន្ធដារគឺជាអ្នកផ្សាភ្ជាប់ទំនាក់ទំនង រវាងអ្នកជាប់ពន្ធជាមួយនិងអង្គភាពពន្ធ ក្នុងការបំពេញបែបបទដាក់លិខិតប្រកាសសារពើពន្ធប្រចាំខែ ប្រចាំឆ្នាំ និងបង់ពន្ធ-អាករទាំងឡាយ បង្ហាញនិងផ្តល់ឯកសាររបាយការណ៍ និងលិខិតគតិយុត្តផ្សេងៗរបស់អ្នកជាប់ពន្ធពាក់ព័ន្ធនឹងពន្ធដារ ជូនរដ្ឋបាលសារពើពន្ធ ស្របតាមបទប្បញ្ញត្តិស្តីពីពន្ធដារ បំពេញរាល់កាតព្វកិច្ចដែលអ្នកជាប់ពន្ធត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ទទួលព័ត៌មានជាប្រចាំអំពីការធ្វើបច្ចុប្បន្នភាព ឬវិសោធនកម្មច្បាប់និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ ជាដៃគូរសហប្រតិបត្តិការល្អ ជាមួយរដ្ឋបាលសារពើរពន្ធ ក្នុងការពង្រីក និងពង្រឹងការផ្តល់សេវា ការអប់រំដល់អ្នកជាប់ពន្ធ ធានាឱ្យបានការអនុវត្តច្បាប់ ព្រមទាំងទប់ស្កាត់សកម្មភាពគេចវេះពន្ធផងដែរ។

នៅក្នុងអង្គពិធីនេះ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ក៏បានផ្តាំផ្ញើដល់បេក្ខជន-បេក្ខនារី ដែលបានប្រឡងជាប់ទាំងអស់ ដែលនឹងក្លាយ ជាភ្នាក់ងារសេវាកម្មពន្ធដារ ត្រូវប្រើប្រាស់ជំនាញវិជ្ជាជីវៈរបស់ខ្លួនឲ្យបានត្រឹមត្រូវ និងមានប្រសិទ្ធិភាពខ្ពស់គោរពតាមក្រមសីលធ៌មវិជ្ជាជីវៈ ព្រមទាំងយកចំណេះដឹង និងបទពិសោធន៍ ល្អៗទៅផ្សព្វផ្សាយបន្តដល់អ្នកជាប់ពន្ធដទៃទៀត ដើម្បីលើក កម្ពស់វប្បធម៌នៃការបង់ពន្ធឲ្យកាន់តែទូលំទូលាយ ក្នុងគោលដៅ ចូលរួមចំណែកកែទម្រង់រដ្ឋបាលសារពើពន្ធ ឲ្យកាន់តែទទួលលទ្ធផលល្អប្រសើរ។

ជាទីបញ្ចប់ឯកឧត្តម គង់ វិបុល ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានជូនពរដល់ឯកឧត្តម លោក-លោកស្រី និងបេក្ខជន-បេក្ខនារី ជ័យលាភីទាំងអស់ ដែលមានវត្តមានក្នុងពិធី ទទួលវិញ្ញាបនបត្រនេះ សូមសមប្រកបនឹងពុទ្ធពរទាំង៤ប្រការគឺ៖ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លៀតឡើយ៕



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ